

# ថ្ងៃបុណ្យអុំទូក

Belgian Development Cooperation

Let's Read
The Asia Foundation

ពាក្យថ្មីនៅក្នុងសៀវភៅនេះ៖ កីឡាករ កាំជ្រួច កត្តិក ជំនឿ ឈ្នះ ដូរទិស ប្រទីប ប្រណាំង ប្រវត្តិ ពេញបូណ៌មី រាំង សំពះព្រះខែ សតវត្ស ហ៊ោ អបអរ អស្ចារ្យ អកអំបុក



គ្រួសារជុំទៅមើលពិធីបុណ្យអុំទូកនៅមុខវាំង ។



ជុំ និងជាតិមើលពិធីអុំទូកយ៉ាងសប្បាយ ។




ពេលចប់ពិធីអុំទូក គេបានត្រឡប់មកផ្ទះជីតាវិញ ។



ជីតាសួរ៖ "សប្បាយទេចៅ?" ជុំ និងជាតិឆ្លើយ៖ "សប្បាយណាស់លោកតា" ។



ជីតាជុំបានឱ្យចៅរៀបរាប់អំពីពិធីបុណ្យអុំទូក ។



ជុំ និងជាតិបានរៀបរាប់ប្រាប់លោកតា៖ "នៅតាម មាត់ទន្លេ
មានមនុស្សច្រើនណាស់មើល ការប្រណាំងទូក" ។



ទូកទាំងនោះស្អាតៗ ហើយលឿនណាស់ ។



អ្នកមើលទូកប្រណាំងបានស្រែកហ៊ោអបអរ អ្នកអុំទូក ។ ខ្ញុំក៏ស្រែកហ៊ោដែរ ។



ជីតាសួរ៖ "តើទូកឈ្នះគេបានអ្វីទៅចៅ?" ជុំឆ្លើយ៖ "អ្នកឈ្នះទទួលបានរង្វាន់" ។



ជីតាសួរ៖ ”ក្រៅពីប្រណាំងទូក តើចៅៗបានឃើញ អ្វីទៀត?”
ជាតិឆ្លើយ៖ ”ពេលយប់ខ្ញុំឃើញកាំជ្រួចស្អាតណាស់” ។



ជុំនិយាយ៖ "ខ្ញុំបានឃើញប្រទីបជាច្រើន" ។ ជាតិបន្ថែម៖ "
ប្រទីបទាំងនោះស្អាតណាស់" ។



ខ្ញុំបានបបួលជុំទៅមើលគេរាំ និងកន្លែងលក់ ផ្សេងៗទៀតផង ។



ជីតានិយាយ៖ ”អ្វីដែលចៅបានរៀបរាប់ មិនខុសពី អ្វីដែលតា
បានឃើញកាលពីនៅក្មេងនោះទេ!” ។ ជុំសួរ៖ ”តើលោកតា
ធ្លាប់ទៅមើលពិធីបុណ្យអុំទូក ដែរឬទេ?”



ជីតាឆ្លើយ៖ ”ពេលតានៅក្មេង តាធ្លាប់ទៅមើល ពិធីបុណ្យអុំទូក និងជាកីឡាករអុំទូកទៀតផង” ។ ជុំ និងជាតិសួរ៖ ”អ្ហា! លោកតាធ្លាប់ជាកីឡាអុំទូក! តើលោកតាធ្លាប់អុំទូកឈ្នះគេដែរឬទេ?”



ជីតាឆ្លើយ៖ ”ពិតមែនហើយ! មើលរូបនេះ!” ។ ជុំ និងជាតិ និយាយ៖ ”អូ! អស្ចារ្យណាស់ លោកតាខ្ញុំ!” ។



បុណ្យអុំទូក បុណ្យអុំទូកមានប្រវត្តិតាំងពីយូរលង់ណាស់មក ហើយ ។ គេតែងប្រារព្ធ ធ្វើបុណ្យនេះជារៀងរាល់ឆ្នាំ ក្នុងខែកត្តិក មានរយៈពេលបីថ្ងៃ ស្របពេលដែល ទឹកទន្លេសាបហូរដូរ ទិសដៅ ហើយក៏ជាពេលព្រះចន្ទពេញបូណ៌មីដែលគេជឿ ថា នឹងនាំមកនូវសំណាងល្អ ។ ក្នុងពិធីនេះមានទូកជាច្រើនចូលរួម ប្រណាំង ។ ទូកទាំងនោះមានការតុបតែងលម្អដោយគំនូរ ក្បាច់រចនាចម្រុះពណ៌យ៉ាង ឆើតឆាយ ។ ក្នុងពិធីនេះមានការ ប្រណាំងទូក បណ្ដែតប្រទីប អកអំបុក និង សំពះព្រះខែ ។

Brought to you by

**The Asia Foundation**

Let's Read is a program of The Asia Foundation that supports early reading skills and habits to develop our next generation of critical thinkers and creative innovators in Asia and the Pacific.

To read more books like this and get further information, visit: letsreadasia.org

Original Story
ថ្ងៃបុណ្យអុំទូក. Author: Belgian Development Cooperation.

Published by Ministry of Education, Youth, and Sports of Cambodia, © Ministry of Education, Youth, and Sports of Cambodia.

Translations: © The Asia Foundation, 2018.